ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ២៧៥/២៣ រ.ប.ក

# របាយការណ៍ត្រីមាសទី៣
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# និងទិសដៅត្រីមាសទី៤ ឆ្នាំ២០២៣

## I. ស្ថានភាពទូទៅ

ក្រសួង ស្ថាប័ន រាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះប្រទេសជាតិ បាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅបណ្តាប្រទេសមួយចំនួន គ្រោះធម្មជាតិ( ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ-១៩ និងមេរោគបម្លែងថ្មី។

ក្រោយពីពិភពលោកកំពុងតែប្រយុទ្ធប្រឆាំងនឹងវិបត្តិជំងឺកូវីដ-១៩ មិនទាន់បានចប់ផង ក៏មានព្រឹត្តិការណ៍ថ្មីមួយទៀត ចាប់ពីខែ កុម្ភៈ ឆ្នាំ២០២២ មកដល់ពេលបច្ចុប្បន្ននេះមានការផ្ទុះសង្គ្រាមរវាងប្រទេសរុស្ស៊ី និងប្រទេសអ៊ុយក្រែន បានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចទូទាំងសកលលោក ដូចជាប្រេង និងឧស្ម័ន បានឡើងថ្លៃខ្ពស់ រហូតធ្វើឱ្យប្រទេសមួយចំនួនមានសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង និងមានវិបត្តិជំពាក់បំណាល់គេដ៏ធ្ងន់ធ្ងរ ដែលមិនអាចដោះស្រាយបាន។

រាជរដ្ឋាភិបាលយើងបាន និងកំពុងតែ យកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ ដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំណែកឯប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឱ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺដ៏ធ្ងន់ធ្ងរថែមទៀត។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាពជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ

ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ បានរៀបចំបន្តពិនិត្យសេចក្តីព្រាងច្បាប់ស្តីពី «អំពើពពោះជំនួស» និងច្បាប់ស្តីពី «ការប្រឆាំងអំពើរត់ពន្ធមនុស្ស»។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពី «ទេសន្តរប្រវេសន៍ការងារកម្ពុជានៅបរទេស»។

#### ២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ» ជាមួយសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «បត្យាប័ន» ជាមួយសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការផ្ទេរទណ្ឌិត» ជាមួយសាធារណរដ្ឋប៉េរូ សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋតួកគី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងព្រះរាជាណាចក្របែលហ្សិក។

### ខ. ការបង្ការ ទប់ស្កាត់

#### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

##### ១.១. ការអប់រំដោយផ្ទាល់

*តារាងសរុបការអប់រំដោយផ្ទាល់*

| បរិយាយ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|
| ការផ្សព្វផ្សាយ និងវេទិកាសាធារណៈ | ៣៩.៥០៨ | ១.៦៧៧.៦០៦ | ៨៤៧.៦២៦ |
| ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ | ៣៣ | ២.២១៤ | ៧៣៣ |
| ការផ្សព្វផ្សាយរបស់អង្គការដៃគូ | ១៩ | ២.២៧៥ | ១.១១៦ |
| សរុប | ៣៩.៥៦០ លើក | ១.៦៨២.០៩៥ នាក់ | ៨៤៩.៤៧៥ នាក់ |

### ១.១.១. ការអប់រំផ្សព្វផ្សាយ និងវេទិកាសាធារណៈ

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៣នេះ ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយ អង្គការដៃគូ ធ្វើការផ្សព្វផ្សាយស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុក ដោយសុវត្ថិភាព វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព**" ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន **៣៩.៥០៨**លើក មានអ្នកចូលរួមសរុប ចំនួន **១.៦៧៧.៦០៦**នាក់ ស្ត្រីចំនួន **៨៤៧.៦២៦**នាក់ (ធៀបនឹងត្រីមាសទី២ មានចំនួន **១.០៩៧.៤៦៩**នាក់ គឺមាន ការកើនឡើងចំនួន **៥៨០.១៣៧**នាក់ ស្មើនឹង**៥២,៨៦%**) ក្នុងនោះ ដូចមានតារាងលម្អិតខាងក្រោម៖

**តារាងការអប់រំផ្សព្វផ្សាយ និងវេទិកាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ២៣១ | ២២.៩១៨ | ១០.១៣៦ | ១.៨១០ | ៥៥.៨៩៩ | ២៦.៩៩៥ |
| | សរុប ក្រសួង ស្ថាប័ន | ២៣១ លើក | ២២.៩១៨ នាក់ | ១០.១៣៦ នាក់ | ១.៨១០ លើក | ៥៥.៨៩៩ នាក់ | ២៦.៩៩៥ នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ២.៨១៨ | ១៦៣.៩៥៣ | ៨៣.៥១០ | ៤.១៨០ | ២៣៦.៦៨៩ | ១២៥.៥៤៨ |
| ៣ | ខេត្តបាត់ដំបង | ២.៣០៤ | ១១១.៧១១ | ៥៨.៣៦៨ | ១.៧០៨ | ៥៩.៨៦៨ | ៣២.១៦៨ |
| ៤ | ខេត្តពោធិ៍សាត់ | ១.០៥០ | ១០០.៩៩១ | ៥៧.០៨៩ | ៣៩០ | ១៨.២០២ | ៨.៦៧៧ |
| ៥ | ខេត្តសៀមរាប | ១.០៧៩ | ៩៤.៧៧៨ | ៥៧.០៨៦ | ៣៣២ | ៩.៦៩៨ | ៥.៨៤៧ |
| ៦ | ខេត្តកំពង់ឆ្នាំង | ២.២០៤ | ៦០.៦៩២ | ៣០.៣១៩ | ១.០៩៥ | ២៩.៨០៥ | ២០.៧៥៤ |
| ៧ | ខេត្តកំពង់ចាម | ៥.៣២៦ | ៣០៤.៨៨៩ | ១៥១.១៦៧ | | | |
| ៨ | ខេត្តព្រះសីហនុ | ១៤៩ | ៦.៦៥៥ | ២.៩៩៦ | ៥ | ៤១៦ | ១៤៩ |
| ៩ | ខេត្តព្រះវិហារ | ២៨ | ២.២៦២ | ១.៣០៦ | | | |
| ១០ | ខេត្តស្វាយរៀង | ៣ | ៦១ | ២៩ | ១.១៧០ | ៣៨.២៥៩ | ២០.២៤៨ |
| ១១ | ខេត្តប៉ៃលិន | ២៦៤ | ៤.៥៦០ | ១.១៧៨ | ១១៧ | ៤.៥៦៤ | ១.១០៨ |
| ១២ | ខេត្តកោះកុង | | | | ៣៣៨ | ៦.៥០០ | ៣.១៨០ |
| ១៣ | ខេត្តកំពត | ២ | ៥៦៤ | ៣៦៥ | | | |
| ១៤ | ខេត្តកំពង់ធំ | ៥៦៣ | ៣៤.៥៦១ | ១៨.៩៣០ | ៨៩ | ៦.២៦៣ | ៣.៣៨៧ |
| ១៥ | ខេត្តតាកែវ | ១.០៤៣ | ៣៨.៧៣៣ | ២០.៨៥៨ | ៣០៨ | ១០.៧៨៥ | ៦.៣០០ |
| ១៦ | ខេត្តក្រចេះ | ៣៣ | ២.២១៦ | ១.២៣៩ | | | |
| ១៧ | ខេត្តកែប | ៧៣ | ១៣.៩៥១ | ៥.១៤៧ | ១៣០ | ៥.៥៧៥ | ៣.១៤៩ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | ៦ | ១៥០ | ១២១ | | | |
| ២០ | ខេត្តរតនគិរី | ៣៣៩ | ១១.៦៧៦ | | ៧៩៣ | ៣០.៧៦៧ | |
| ២១ | ខេត្តព្រៃវែង | ៦០៣ | ៤៩.៨៤៨ | ២៣.២៧២ | ៦១ | ២.៦៤៣ | ១.៤៦៤ |
| ២២ | ខេត្តត្បូងឃ្មុំ | ៤.១៧៤ | ៥៩.៦០៦ | ២៦.១៦៥ | ២.២២៦ | ៣១.៤២៥ | ១៣.២១២ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ២.០៦៦ | ៣៣.៩៣៧ | ១៩.៥៤៥ | ៣៩៤ | ១០.៦៧០ | ៦.២៣២ |
| ២៤ | ខេត្តឧត្តរមានជ័យ | ៥ | ៨៦៦ | ៣៨២ | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| | សរុប រាជធានី-ខេត្ត | ២៤.១៣២ | ១.០៩៦.៦៦០ | ៥៥៩.០៧២ | ១៣.៣៣៥ | ៥០២.១២៩ | ២៥១.៤២៣ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ៣៩.៥០៨ លើក | | ចំនួនមនុស្សសរុប ១.៦៧៧.៦០៦ នាក់ | | ចំនួនស្ត្រី ៨៤៧.៦២៦ នាក់ | |

១.១.២. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- **ខេត្តកំពង់ឆ្នាំង៖**
  - មន្ទីរអប់រំ យុវជន និងកីឡា បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងការជួញដូរមនុស្ស តាមរយៈកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ដល់ប្រធានការិយាល័យអប់រំ រដ្ឋបាលក្រុង ស្រុកទាំង៨ និងសិស្សានុសិស្ស នៅក្នុងពេលគោរពទង់ជាតិមុនចូលរៀន និងនៅក្នុងមេរៀនដែលពាក់ព័ន្ធ ចំនួន **១៧**លើក។
  - ស្រុកទឹកផុសបានចុះផ្សព្វផ្សាយច្បាប់ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស តាមរយៈកិច្ចប្រជុំគណៈបញ្ជាការឯកភាព កិច្ចប្រជុំ គ.ក.ស.ក និងកិច្ចប្រជុំសមាគមនារីដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ចំនួន ០៣លើក មានអ្នកចូលសរុបចំនួន **១៣១**នាក់ ស្រី **២២**នាក់។
  - ស្រុកសាមគ្គីមានជ័យ បានផ្សព្វផ្សាយស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ តាមរយៈកិច្ចប្រជុំ គ.ក.ស.ក ប្រចាំខែ មានអ្នកចូលរួម **៤៨**នាក់ ស្រី **២៣**នាក់។
- **ខេត្តកំពង់ចាម៖ រដ្ឋបាលស្រុកចំការលើ** សហការជាមួយអង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍ ផ្សព្វផ្សាយអំពីវិធីបង្ការការពារជំងឺ covid-19 និងការចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន០៣លើក ដែលមានអ្នកចូលរួមសរុប **២២៨**នាក់ ស្រី**១៧៨**នាក់។
- **ខេត្តបន្ទាយមានជ័យ៖**
  - **អង្គការតំណក់ទឹក** បានចុះធ្វើបណ្ណាល័យចល័ត ដើម្បីអប់រំដល់ក្រុមយុវជន និងគ្រួសារ ស្តីពីចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន ០៣លើក មានអ្នកចូលរួម **៣៩១**នាក់ ស្រី**២០៥**នាក់។
  - **អង្គការអន្តរជាតិទេសន្តរប្រវេស៍(IOM)៖** បានប្រឹក្សាយោបល់ដោយផ្ទាល់ ជាលក្ខណៈឯកជនជាមួយពលករ ចំនួន០៣លើក មានពលករទេសន្តរប្រវេសន៍ចំនួន **១២៧**នាក់(ស្រី**៣០**នាក់)។
  - **អង្គការកល្យាណមិត្ត៖** កម្មវិធីអប់រំផ្សព្វផ្សាយបំណិនជីវិត ការចំណាកស្រុកប្រកបដោយសុវត្ថិភាព ០៣លើក និងសម្ភារៈអនាម័យប្រជាពលរដ្ឋក្នុងសហគមន៍ចំនួន **១.២៨៩**នាក់ ស្រី**២៧៥**នាក់។

១.១.៣. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

- **ខេត្តបន្ទាយមានជ័យ៖ អង្គការសាម៉ារីតាន់ ភីសសង្គ្រោះអន្តរជាតិ** បានអប់រំសហគមន៍អំពីការចំណាកស្រុកសុវត្ថិភាពដល់ពលករចំនួន **៨១៦**នាក់ ស្រី**៤១៩**នាក់ កុមារ **៥៤**នាក់(កុមារី **២៦**នាក់)។
- **ខេត្តកណ្តាល៖ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ និងអង្គការខេមរៈអភិវឌ្ឍសហគមន៍** សហការជាមួយអាជ្ញាធរក្រុងសំពៅពូន បានធ្វើការផ្សព្វផ្សាយស្តីពី ការទប់ស្កាត់ការជួញដូរមនុស្ស ធ្វើនៅសង្កាត់ព្រែកស្តី សង្កាត់សំពៅពូន សង្កាត់ឈើខ្មៅ ជូនដល់ក្រុមគោលដៅចំនួន **៣៦២**នាក់ ស្រី **១១៦**នាក់។
- **ខេត្តសៀមរាប៖**
  - **អង្គការមូលនិធិអេ២១** បានផ្សព្វផ្សាយអប់រំស្តីពី អំពើជួញដូរមនុស្ស និងសុវត្ថិភាពប្រព័ន្ធអនឡាញនៅតាមសហគមន៍ ចំនួន ០៧លើក មានអ្នកចូលរួមសរុប **១១៦**នាក់ ស្រី**៥០**នាក់។
  - **អង្គការទេសន្តរប្រវេសន៍ (IOM)** បានធ្វើការផ្សព្វផ្សាយការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជ្រើសរើសបេក្ខជនចូលរៀនជំនាញវិជ្ជាជីវៈ ចំនួន**១០**លើក មានអ្នកចូលរួមសរុប **៩២៧**នាក់ ស្រី **៥០៥**នាក់។

១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញផ្តល់បទសម្ភាសន៍នៅស្ថានីយ៍ទូរទស្សន៍បាយ័ន្ត ដើម្បីផលិតបទយកការណ៍ ស្តីពីអំពើជួញដូរមនុស្សនៅកម្ពុជា ដើម្បីដាក់បញ្ចូលក្នុងទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០២៣ ក្រោមប្រធានបទ «**មនុស្សមានសីលធម៌ សង្គមមានសុវត្ថិភាព គ្មានអំពើជួញដូរមនុស្ស**»។

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធ ស្តីពីការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរយៈគេហទំព័រហ្វេសប៊ុក មានអ្នកចូលទស្សនាចំនួន **៨.៣៧៩**នាក់។
- **លេខាធិការដ្ឋាន គ.ខ.ប.ជ** ផ្សព្វផ្សាតាមប៉ុស្តិ៍វិទ្យុ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សសរុបចំនួន **៣៧៣**លើក ក្នុងនោះមាន៖ ខេត្តត្បូងឃ្មុំ **១៨០**លើក សៀមរាប **២៨៤**លើក ព្រៃវែង **១០០**លើក កំពង់ធំ **០១**លើក និងខេត្តកំពង់ចាម **១១**លើក។

**១.៣. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)**

- **ខេត្តបន្ទាយមានជ័យ៖**
  - **អង្គការសាម៉ារីតាន់ភឺស** ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់មនុស្សចំនួន **១.០២០**នាក់(ស្រី**៣៥២**នាក់) កុមារ **១៥៨**នាក់(កុមារី**៩៨**នាក់)។
  - **អង្គការ UNFPA** ចែកខិត្តប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងបានចែកកញ្ចប់ឃីតចំនួន **១១៨**កញ្ចប់ដល់ពលករ។
  - **អង្គការ UN WOMEN** ចែកខិត្តប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងចែកកញ្ចប់ឃីតចំនួន **៧៧**កញ្ចប់ដល់ពលករ។
- **ខេត្តបាត់ដំបង៖ អង្គការសាម៉ារីតាន់ភឺស** បានចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស និងខិត្តប័ណ្ណស្តីពីការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ សរុបចំនួន **២.៧៤២**សន្លឹក។
- **ខេត្តសៀមរាប៖**
  - **រដ្ឋបាលស្រុកពួក** បានធ្វើការចែកខិតប័ណ្ណស្តីពី ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ បានចំនួន **២.៧១៤**ខិតប័ណ្ណ។
  - **វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ** សហការជាមួយ**អង្គការទេសន្តរប្រវេសន៍ (IOM)** បានចែកខិតប័ណ្ណធ្វើស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជ្រើសរើសបេក្ខជនចូលរៀនជំនាញវិជ្ជាជីវៈ បានចំនួន **១.២៥៦**ខិតប័ណ្ណ។
- **ខេត្តក្រចេះ៖** អង្គការសកម្មភាពដើម្បីកុមារ (Aple) បានបោះពុម្ពសៀវភៅច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ និងផ្តល់បន្ថែមនូវសៀវភៅគោលការណ៍ប្រតិបត្តិបែបកុមារមេត្រីសម្រាប់សម្ភាសន៍ និងគាំទ្រកុមាររងគ្រោះដោយអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ដល់មន្ត្រីនគរបាលទើបជ្រើសរើសថ្មី ចំនួន៧៤នាក់ ស្រី២៣នាក់ ដោយម្នាក់ៗទទួលបានសៀវភៅចំនួន០៣ក្បាល។

**១.៤. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ**

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមធ្វើបាឋកថាចែករំលែកបទពិសោធន៍លើប្រធានបទស្តីពី "**ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស នៅក្នុងប្រទេសកម្ពុជា**" ដល់សិក្ខាកាមកម្រិត២ ជំនាន់ទី៤ នៅសាលាបណ្ឌិតសភានគរបាលជាតិ ចំនួន **៣៦១**នាក់ (ស្រី **៥៧**នាក់) ។
- **ខេត្តកំពង់ចាម៖** បានចូលរួមជាវាគ្មិននៅវិទ្យុ **១២**លើក ស្តីពីការចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងនោះមានតំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ១០លើក មន្ទីរកិច្ចការនារី ០១លើក ស្នងការដ្ឋាននគរបាល ០១លើក។

- **ខេត្តក្រចេះ៖** លោកស្រីឧត្តមសេនីយ៍ត្រី ស្នងការរង បានចូលរួមធ្វើបទបង្ហាញក្នុងវគ្គបណ្តុះបណ្តាលពង្រឹងតួនាទី ភារកិច្ចរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាល ស្តីពីវិធានការទប់ស្កាត់អំពើជួញដូរមនុស្ស និងកិច្ចការពារកុមារ គោលគំនិតយេនឌ័រ និងបានចែកជូនដល់សិក្ខាកាមនូវសៀវភៅគោលការណ៍ប្រតិបត្តិបែបកុមារមេត្រីសម្រាប់សម្ភាសន៍ និងគាំទ្រកុមាររងគ្រោះដោយអំពើរំលោភបំពានកេងប្រវ័ញ្ចផ្លូវភេទ ដែលឧបត្ថម្ភពីអង្គការសកម្មភាពដើម្បីកុមារ (Aple) ចំនួន១០០ក្បាល ដល់សិក្ខាកាមចូលរួមចំនួន **១៥២**នាក់ ស្រី**២៩**នាក់។
- **ខេត្តព្រៃវែង៖** តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមធ្វើបទបង្ហាញក្នុងវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ព្រមទាំងគោលនយោបាយប្រាក់សោធន ចំនួន ០៧វគ្គ មានអ្នកចូលរួមសរុប **១៩២**នាក់ ស្រី **១០៦**នាក់។
- **ខេត្តកំពង់ធំ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយការិយាល័យជំនាញ នៃស្នងការដ្ឋាននគរបាលខេត្ត ចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិនៅវិទ្យុជាតិខេត្តកំពង់ធំ ០១លើក ស្តីពីការផ្សព្វផ្សាយច្បាប់ ការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ។

## ២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ២.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុក ទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន **២២៤.៨៨៥**នាក់ (ស្រី **៩៩.៦២០**នាក់) អនីតិជន **៣.៤៥០**នាក់(ស្រី**១.២២៨**នាក់) ក្នុងនោះមាន៖
  - ស្របច្បាប់ ចំនួន **១៧០.៣៨៩**នាក់(ស្រី**៧៧.៨៥៧**នាក់) អនីតិជន **២៥១**នាក់(ស្រី**៧១**នាក់)
  - មិនស្របច្បាប់ចំនួន **៥៤.៣២៨**នាក់(ស្រី**២១.៧១២**នាក់) អនីតិជន **៣.១៦៧**នាក់ (ស្រី **១.១៤៤**នាក់)។
  - ដាច់ការទាក់ទងចំនួន **១៦៨**នាក់ (ស្រី**៥១**នាក់) អនីតិជន **៣២**នាក់(ស្រី **១៣**នាក់)។
- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯងពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន **៣៨២.០០១**នាក់ (ស្រី**១៧៣.១១៥**នាក់) អនីតិជន **១.១៨២**នាក់ (ស្រី **៥០២**នាក់)។

*តារាងស្ថិតិពលរដ្ឋខ្មែរដែលវិលត្រឡប់ពីក្រៅប្រទេស*

| **បរិយាយ** | **ចំនួនមនុស្ស** | | **អនីតិជន** | |
|---|---|---|---|---|
| | **ប្រុស** | **ស្រី** | **ប្រុស** | **ស្រី** |
| ខែកក្កដា | ១២៧.៧២៦ | ៥៩.២៦៨ | ៣៦៤ | ១៨១ |
| ខែសីហា | ១២៩.៩៤១ | ៥៧.៦៥០ | ៤០៧ | ១៦១ |
| ខែកញ្ញា | ១២៤.៣៣៤ | ៥៦.១៩៧ | ៤១១ | ១៦០ |
| **សរុបរួម** | ៣៨២.០០១ នាក់ | **១៧៣.១១៥ នាក់** | **១.១៨២ នាក់** | **៥០២ នាក់** |

- **មណ្ឌលសំចតប៉ោយប៉ែត** ពលករចំណាកស្រុកដែលត្រឡប់មកពីប្រទេសថៃ ចំនួន **១.២៤១**នាក់ (ប្រុស**៦២៩**នាក់ ស្រី**៤៤៩**នាក់ កុមារ**៩១**នាក់ កុមារី**៧២**នាក់)។

### ២.៣. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ សៀមរាប ស្វាយរៀង ក្រចេះ និងខេត្តកែប បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ជារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា បានចំនួន **៦១៨**គោលដៅ មនុស្សចំនួន **៣.៤៣៨**នាក់ (ស្រី**២.៥២៤**នាក់)។

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ បាត់ដំបង កំពត ព្រៃវែង ព្រះវិហារ និងខេត្តតាកែវ បានល្បាតឃ្លាំមើលគោលដៅសង្ស័យប្រព្រឹត្តបទល្មើស ចំនួន ៨៩លើក។

**២.៤. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

▪ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តច្បាប់**) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យសុំចុះបញ្ជីការរៀបអាពាហ៍ពិពាហ៍ បានចំនួន **៤៨៤**នាក់(ស្រី៣០នាក់) មាន **១៥**សញ្ជាតិ ហើយបានវាយតំលៃបញ្ជូនឱ្យក្រុមការងារប្រកចេញចូលតែមួយបានចំនួន **៦៧២**នាក់(ស្រី៤៣នាក់)។ បានប្រមូលព័ត៌មានពីសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅក្រៅប្រទេសតាមរយៈទូរស័ព្ទ ចំនួន **១៦**នាក់(ស្រី)(កូរ៉េខាងត្បូង ១៤នាក់ ចិន ០២នាក់) មានសេចក្តីសុខធម្មតា។

**៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **ខេត្តព្រះសីហនុ៖**
  - ផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានដាក់បណ្តាញម៉ូតូឌុបនិងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ ផ្នែកភ្នាក់ងារទេសចរណ៍ សរុបចំនួន ១.១៣៣នាក់។
- **ខេត្តសៀមរាប៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះតាមដានត្រួតពិនិត្យ និងស្រង់ទិន្នន័យកុមារ និងគ្រួសារ នៅតាមសិប្បកម្មផលិតឥដ្ឋ ចំនួន ១២កន្លែង នៅក្នុងស្រុកជីក្រែង និងស្រុកក្រឡាញ់ ដែលមានកម្មករសរុប ៣៧៨នាក់ ស្រី២០៦នាក់ ដោយរកឃើញថាពុំមានការប្រើប្រាស់កម្លាំងពលកម្មជាកុមារទេ។
- **ខេត្តបន្ទាយមានជ័យ៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះផ្សព្វផ្សាយការទប់ស្កាត់ពលកម្មកុមារ ដល់គោលដៅ ក្រុងប៉ោយប៉ែត សួនឧស្សាហ៍កម្មក្រុងសិរីសោភ័ណ កាស៊ីណូ និងសហគ្រាស ចំនួន១៨៥កន្លែង។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ១. ការងារអនុវត្តច្បាប់

**១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន **៣៧**ករណី/៤០ករណី (ធៀបនឹងត្រីមាសទី២ ថយ០៣ករណី ស្មើនឹង **៧,៥%**) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **៤៨**នាក់ (ស្រី**១០**នាក់) ជនសង្ស័យជាអនីតិជន០៧នាក់ និងជនបរទេស០៥នាក់(ចិន២ វៀតណាម២ និងប៉ាគីស្ថាន១)។

សង្គ្រោះជនរងគ្រោះ ចំនួន **១០៧**នាក់(ស្រី**៧៧**នាក់) មាន៖ អាយុក្រោម១៥ឆ្នាំ **២៧**នាក់ អាយុ១៥-១៧ ឆ្នាំ ០៩នាក់ និងអាយុ១៨ឆ្នាំឡើង **៧១**នាក់ (ប្រគល់ឱ្យសង្គមកិច្ច **៣១**នាក់ និងប្រគល់ឱ្យគ្រួសារ **៦៦**នាក់) ក្នុងនោះចែកជា៖

❖ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ១០ករណី/០៦ករណី ឃាត់ខ្លួនជនសង្ស័យចំនួន **១៦**នាក់ ជនសង្ស័យជាអនិតិជន ០៣ នាក់ និងជនបរទេស ០៣នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៤៨នាក់(ស្រី**១៩**នាក់) មាន៖ អាយុក្រោម១៥ឆ្នាំ ០៣ នាក់ អាយុ១៥-១៧ឆ្នាំ ០២នាក់ និងអាយុ១៨ឆ្នាំឡើង ៤៣នាក់ (ប្រគល់ឱ្យសង្គមកិច្ច ០៦នាក់ និងប្រគល់ឱ្យគ្រួសារ ៤២នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ (ស្រី) | ជនសង្ស័យ | បរទេស |
|---|---|---|---|---|
| -ការយកចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន | ០៥ | ០៩ (០៦) | ០៩ | |
| -ការនាំចេញដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ចន៍ | ០២ | ៣៦ (១០) | ០៣ | ចិន០២<br>ប៉ាគីស្ថាន០១ |
| -ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០១ | ០១ (០១) | ០២ | |
| -ការទិញពេស្យាចារកុមារ | ០២ | ០២ (០២) | ០២ | |
| *សរុប* | *១០ ករណី* | *៤៨ (១៩) នាក់* | *១៦ នាក់* | *០៣ នាក់* |

❖ **ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន **២៧**ករណី/**៣៤**ករណី ឃាត់ខ្លួនជនសង្ស័យចំនួន **៣២**នាក់( ស្រី**០៦**នាក់ ) អនីតិជន **០៣** នាក់ និងជនបរទេស**០២**នាក់។ សង្គ្រោះជនរងគ្រោះចំនួន **៥៩**នាក់(ស្រី**៥៨**នាក់) មានៈ អាយុក្រោម១៥ឆ្នាំ **២៤** នាក់ អាយុ១៥-១៧ឆ្នាំ **០៧**នាក់ និងអាយុ១៨ឆ្នាំឡើង **២៨**នាក់ (ប្រគល់ឱ្យសង្គមកិច្ច **៣៥**នាក់ និងប្រគល់ឱ្យគ្រួសារ **២៤**នាក់ )។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ (ស្រី) | ជនសង្ស័យ | បរទេស |
|---|---|---|---|---|
| -ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ០៣ | ៣៤ (៣៤) | ០៦ | វៀតណាម០១ |
| -សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០១ (០១) | ០១ | |
| -រូបភាព និងសម្ភារៈអាសអាភាស | ០១ | ០២ (០១) | ០១ | វៀតណាម០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៩ | ១៩ (១៩) | ២១<br>អនី.០៣ | |
| -អំពើអាសប្រឆាំងនឹងមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៣ (០៣) | ០៣ | |
| *សរុប* | *២៧ ករណី* | *៥៩ (៥៨) នាក់* | *៣២ នាក់*<br>*អនីតិជន០៣* | *០២ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន ( ផ្លូវគោក និង ផ្លូវអាកាស ) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

**១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់**

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា ចំនួន**៧៧**នាក់( ស្រី**៧៤**នាក់ ) មកពីចិន **៧២**នាក់ និងម៉ាឡេស៊ី **០៥**នាក់ ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទ:/បង្ខំ **៧១**នាក់ ករណីជួញដូរកម្លាំងពលកម្ម **០៦**នាក់។
- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
  - **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនៈ** បានសម្ភាសន៍ជនរងគ្រោះ ដែលបានវិលត្រឡប់មកពីក្រៅប្រទេសតាមព្រលានយន្តហោះអន្តរជាតិភ្នំពេញ ចំនួន **៨៩**នាក់( ស្រី**៨៧**នាក់ ) រួមមានៈ
    - ប្រទេសចិន ៨៨នាក់( ស្រី៨៧នាក់) ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទ: ៤២នាក់ និងស្នាក់នៅខុសច្បាប់ ៤៦នាក់។
    - ប្រទេសម៉ាឡេស៊ី ០១នាក់ ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម។

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ សរុបចំនួន **២៥**លើក មនុស្សចំនួន **២២៧**នាក់(ស្រី **១២៣**នាក់ កុមារ**១១៤**នាក់ កុមារី **៤២**នាក់) ក្នុងនោះមាន៖
  - **ខេត្តស្វាយរៀង៖** តាមច្រកអន្តរជាតិបាវិត ចំនួន **១២**លើក មនុស្សចំនួន **២០៥**នាក់(ស្រី **១១៧**នាក់ កុមារ**១១៣**នាក់ កុមារី**៤២**នាក់)។
  - **ខេត្តព្រះវិហារ៖** តាមច្រកអានសេះ ចំនួន **០២**លើក មនុស្ស **០៥**នាក់(ស្រី **០១**នាក់)។
  - **ខេត្តកោះកុង៖** តាមច្រកព្រំដែនអន្តរជាតិចាំយាម ចំនួន **១១**លើក មនុស្សចំនួន **១៧**នាក់(ស្រី **០៥**នាក់) អនីតិជន **០១**នាក់។

**២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សទៅមណ្ឌលស្តារនីតិសម្បទា សរុបចំនួន **៩៧**នាក់(ប្រុស **០៣**នាក់ ស្រី**៩២**នាក់ កុមារី **០២**នាក់) និងបានបញ្ជូនជនរងគ្រោះជាជនជាតិវៀតណាមទៅប្រទេសកំណើត ចំនួន **៣៥**នាក់ ស្រី**១០**នាក់។

**៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សត្រឡប់ទៅសហគមវិញចំនួន **០២**នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ១. ការងារបណ្តុះបណ្តាល

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ បើកវគ្គបណ្តុះបណ្តាលចំនួន **២៥**វគ្គ មានសិក្ខាកាមចូលរួមសរុប **១.៧២៥**នាក់ (ស្រី**៨៦០**នាក់) ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ សមាជិកគ.រ.ប.ជ/គ.ខ.ប.ជ ដូចមានក្នុងតារាងវគ្គបណ្តុះបណ្តាលខាងក្រោម៖

**តារាងវគ្គបណ្តុះបណ្តាល**

ក្រសួង ស្ថាប័ន បានសហការជាមួយស្ថានទូត ក្រុមហ៊ុន សហគ្រាស អង្គការដៃគូពាក់ព័ន្ធមាន៖ អង្គការសុវណ្ណភូមិ អង្គការ IOM អង្គការមូលនិធិ A21 អង្គការហាកា អង្គការ IJM បើកវគ្គបណ្តុះបណ្តាលទាំងទ្រឹស្តី និងការអនុវត្ត ស្តីពី៖
- ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សាលើស្ត្រី និងកុមារ ការកេងកម្លាំងពលកម្ម ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទូទាំងប្រទេស។
- ជំនាញទុនគន្លឹះក្នុងការស្វែងរកការងារ និងបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស។
- ប្រធានបទពាក់ព័ន្ធនឹងសុវត្ថិភាពអ៊ីនធឺណិត និងកិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត។

| ល.រ | សកម្មភាពរបស់ថ្នាក់ជាតិ | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមនារី |
|---|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | ០២ | ១២៩ | ៤៩ |
| | **សរុបសកម្មភាពថ្នាក់ជាតិ** | **០២** | **១២៩** | **៤៩** |
| **ល.រ** | **សកម្មភាពរបស់ថ្នាក់ក្រោមជាតិ** | **ចំនួនវគ្គ** | **សិក្ខាកាមសរុប** | **សិក្ខាកាមនារី** |
| ១ | ខេត្តស្វាយរៀង | ១១ | ២១៦ | ១៤៩ |
| ២ | ខេត្តកំពង់ឆ្នាំង | ០១ | ២៦៨ | ៨៩ |
| ៣ | ខេត្តសៀមរាប | ០៣ | ៩២ | ៤៥ |
| ៤ | ខេត្តបន្ទាយមានជ័យ | ០១ | ៣៣២ | ១២៦ |
| ៥ | ខេត្តព្រះវិហារ | ០១ | ៩៥ | ៤៧ |

| | | | | |
|---|---|---|---|---|
| ៦ | ខេត្តព្រះសីហនុ | ០៣ | ១០៨ | ៨៧ |
| ៧ | ខេត្តពោធិ៍សាត់ | ០១ | ៣៥ | ២០ |
| ៨ | ខេត្តកោះកុង | ០១ | ៦០ | ០៩ |
| ៩ | ខេត្តបាត់ដំបង(អង្គការសាម៉ារីតាន់ភឺស) | ០១ | ៣៩០ | ២៣៩ |
| | **សរុបសកម្មភាពថ្នាក់ក្រោមជាតិ** | **២៣** | **១.៥៩៦** | **៨១១** |
| | ***សរុបរួម*** | ***២៥*** | ***១.៧២៥*** | ***៨៦០*** |

**២.សិក្ខាសាលា**

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** សហការជាមួយ៖
  - **អង្គការ JICA** រៀបចំសិក្ខាសាលា លទ្ធផលស្រាវជ្រាវ លើគម្រោងបង្កើនសមត្ថភាពមន្ត្រីជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជូនគណៈកម្មការគម្រោង(Joint Coordinating Committee) ដែលរដ្ឋាភិបាលជប៉ុន។
  - **អង្គការ IOM** រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ការធ្វើបច្ចុប្បន្នភាពកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីនីតិប្រតិបត្តិការបទដ្ឋាន (SOP) ក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** សហការជាមួយ៖
  - **អង្គការ IOM (UN MIGRATION)** រៀបចំសិក្ខាសាលាស្តីពី ការបង្កើតនីតិវិធីបទដ្ឋាននៃយន្តការបញ្ជូនថ្នាក់ជាតិសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនទេសន្តរប្រវេសន៍ងាយរងគ្រោះ នៅសណ្ឋាគារអូឡាំព្យា មានសិក្ខាកាមចូលរួម **៤៥**នាក់ ស្រី**១៣**នាក់។
  - **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងឧបត្ថម្ភដោយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) និងអង្គការសម្ព័ន្ធចាប់ដៃ បានរៀបចំសិក្ខាសាលាបច្ចេកទេស ស្តីពី "យន្តការបញ្ជូនបន្តថ្នាក់ជាតិ ពាក់ព័ន្ធអំពើជួញដូរមនុស្ស" នៅសណ្ឋាគារកាំបូឌីយ៉ាណា មានសិក្ខាកាមចូលរួមចំនួន **៦៦** នាក់ ស្រី**៣៧**នាក់។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ១. ក្នុងប្រជុំក្នុងប្រទេស

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំ **១**.កិច្ចប្រជុំពិភាក្សាអំពីការត្រៀមរៀបចំ ទិវាជាតិអន្តរសាសនាដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា លើកទី៧ ចំនួន **០៣**លើក ដោយមានការនិមន្តនិងអញ្ជើញចូលរួម **៦២**អង្គ/នាក់ ស្រី**១៦**នាក់។ **២**.កិច្ចប្រជុំពិភាក្សាស្តីពី ការផលិតសារជាសម្លេង សម្រាប់ផ្សព្វផ្សាយតាមប្រព័ន្ធទូរស័ព្ទចល័ត (Calltune) នាឱកាសប្រារព្ធទិវាជាតិអន្តរសាសនា ។ **៣**.កិច្ចប្រជុំក្រុមការងារបច្ចេកទេស ដើម្បីពិភាក្សាអំពីការធ្វើបច្ចុប្បន្នភាពប្រព័ន្ធបញ្ជូនជនរងគ្រោះសម្រាប់ការរៀបចំគោលការណ៍បែបបទនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្សេងៗ អ្នកចូលរួមចំនួន **១២**នាក់(ស្រី **០៤**នាក់)។ **៤**.កិច្ចប្រជុំចង្អៀតក្រុមការងារ

បច្ចេកទេស ដើម្បីឆ្លើយតបនឹងសំណួរ របស់ស្ថានទូត នៃសាធារណរដ្ឋកូរ៉េ ស្តីពីអាពាហ៍ពិពាហ៍រវាង ពលរដ្ឋកម្ពុជា និងពលរដ្ឋកូរ៉េ អ្នកចូលរួមចំនួន **១៣**នាក់(ស្រី ០៤នាក់)។ **៥.**កិច្ចប្រជុំបច្ចេកទេស ជាមួយក្រុមការងារនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីពិភាក្សាអំពីការ រៀបចំយន្តការបញ្ជូនជនរងគ្រោះថ្នាក់ជាតិ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៦.**កិច្ចប្រជុំស្តីពីលទ្ធ ផលនៃការពិនិត្យ លើកំណែព្រះរាជក្រឹត្យ អនុក្រឹត្យ និងសេចក្តីសម្រេចផ្សេងៗ របស់ គ.ជ.ប.ជ មុន ធ្វើរបាយការណ៍ ទៅឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី។ **៧.**កិច្ចប្រជុំដើម្បីធ្វើប្រតិកម្ម ឆ្លើយតបទៅនឹងរបាយការណ៍របស់ ការិយាល័យអង្គការសហប្រជាជាតិ (OHCHR) នៅទីស្តីការ ក្រសួងមហាផ្ទៃ។ ៨.កិច្ចប្រជុំក្រុមគ្រូឧទ្ទេសនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ត្រៀមចុះទៅបណ្តុះ បណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប សម្រាប់ខេត្តកំពង់ចាម និងកំពត នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

### ២.កិច្ចប្រជុំក្រៅប្រទេស

- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** បានចាត់បញ្ជូន លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីវលក្ខិណា** អគ្គលេខាធិការរង លោកឧត្តមសេនីយ៍ត្រី **តែ សុជាតេ** អគ្គលេខាធិការរង និងលោកឧត្តមសេនីយ៍ត្រី **អ៊ិន មាន** ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរ ជាតិ ដើម្បីចូលរួមកិច្ចប្រជុំតុមូលថ្នាក់តំបន់ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ ដើម្បីបង្ការអំពើជួញដូរ មនុស្ស បណ្តាលមកពីការរំលោភបំពានតាមប្រព័ន្ធបច្ចេកវិទ្យា នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី មានសមាសភាពចូលរួមសរុប **៧០**រូប មកពីប្រទេសចិន ស្រីលង្កា ឥណ្ឌា អាមេរិក អូស្ត្រាលី កេនយ៉ា។

### ៣. ការទទួលជួបពិភាក្សាការងារ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានទទួលជួបពិភាក្សាការងារ ជាមួយ៖ **១.**លោកស្រី **គ្រីស្ទីន ផាកូ** ប្រធានបេសកកម្មរបស់អង្គការ IOM ប្រចាំប្រទេសកម្ពុជា និងសហការី នៅ សាលប្រជុំគ.ជ.ប.ជ។ **២.**តំណាងអង្គការវីនរ៉ក់អន្តរជាតិ ដើម្បីពិភាក្សាអំពីកិច្ចសហការរវាង គណៈកម្មា ធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការវីនរ៉ក់អន្តរជាតិក្នុងអាណត្តិថ្មីនៃរាជរដ្ឋាភិបាល កម្ពុជា។ ៣.តំណាងអង្គការអាស៊ានអាក់ (ASEAN-ACT) ដើម្បីពិភាក្សាអំពីកិច្ចសហការរវាង គណៈ កម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការអាស៊ានអាក់ ក្នុងអាណត្តិថ្មី។ ៤.ប្រតិភូនៃ ស្នងការនគរបាលប្រទេសវៀតណាម ដឹកនាំដោយ ឯកឧត្តម ឧត្តមសេនីយ៍ត្រី **គៀង វីន** ស្នងការរង នគរបាល ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជួយសង្គ្រោះជនរង គ្រោះ តាមខេត្តជាប់ព្រំដែនប្រទេសកម្ពុជា-វៀតណាម។
- **ខេត្តត្បូងឃ្មុំ៖** មន្ត្រីជំនាញនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានជួបប្រជុំពិភាក្សា ជាមួយ៖ **១.**អង្គការ JICA ដើម្បីសម្រេចជ្រើសរើសយកខេត្តត្បូងឃ្មុំសម្រាប់អនុវត្តគម្រោងប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ក្នុងចំណោមខេត្តចំនួន០៤ ដែល JICA នឹងត្រូវជ្រើសរើស។ **២.**បានជួបប្រជុំពិភាក្សា ជាមួយអង្គការសម្ព័ន្ធចាប់ដៃ និងអង្គការសេចក្តីសង្ឃឹមពិភពលោកអន្តរជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ក្នុងនោះអង្គការទាំងពីក៏បានបង្ហាញពីគម្រោង និងសកម្មភាពរបស់ខ្លួនដែលបាន កំពុងអនុវត្តនាពេលបច្ចុប្បនេះ។

## គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំង ប្រទេសគឺ **១០៦**លើក មានអ្នកចូលរួមសរុប **២.៨០៤**នាក់(ស្រី **១.៣២៧**នាក់) ក្នុងនោះមាន គណៈកម្មាធិការ ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **៣៣**លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត **៧៣**លើក។**(ឧបសម្ព័ន្ធ១)**

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។

### គ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅត្រីមាសទី៤ ឆ្នាំ ២០២៣

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការឥតពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៨. បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍ ការងារឆ្លងដែនមិនប្រក្រតី**" ។

៩. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១០. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១១. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ........................ខែ..............ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី..............ខែ....................គ.ស ២០២៣

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ_ប៊ុនអេង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ អភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"**ដើម្បីគោរពជូនជាសេចក្តីរាយការណ៍**"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

-**ដើម្បីជូនជ្រាប**-

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ១០៦លើក) មនុស្សចំនួន ២.៨០៤នាក់ (ស្រី ១.៣២៧នាក់)

<table>
<tr><th>ស្ថាប័ន<br>សម្របសម្រួល</th><th>សកម្មភាព</th></tr>
<tr><td>គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>(គ.ជ.ប.ជ)</td><td>
▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជាអធិបតី៖<br>
- សិក្ខាសាលាផ្សព្វផ្សាយអនុសញ្ញាអាស៊ានស្តីពី ការប្រឆាំងនឹងការជួញដូរមនុស្សជាពិសេសស្ត្រីនិងកុមារ (ACTIP) សហការរៀបចំដោយក្រសួងយុត្តិធម៌ និងកម្មវិធីអាស៊ានអូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស នៅបណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា។<br>
- សិក្ខាសាលាបញ្ចប់សេចក្តីព្រាងផែនការសកម្មភាព ស្តីពីសុខភាពជនសន្តប្រវេសន៍ ឆ្នាំ២០២៣-២០២៥ សហការរៀបចំដោយក្រសួងសុខាភិបាល និងអង្គការ IOM សិក្ខាសាលានេះផងដែរមានសមាសភាពចូលរួមចំនួន៣ប្រទេស (កម្ពុជា ថៃ ឡាវ)។<br>
- សន្និបាតប្រចាំឆ្នាំនៃអង្គការសម្ព័ន្ធចាប់ដៃលើកទី៣៧ ក្រោមប្រធានបទ កម្លាំងនៃភាពជាដៃគូ ដែលរៀបចំដោយអង្គការសម្ព័ន្ធចាប់ដៃ និងមាន៥៦អង្គការកំពុងធ្វើការប្រឆាំងការជួញដូរមនុស្ស ក្នុងរាជធានី ខេត្តចំនួន១៤។<br>
▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញ៖<br>
- ចូលរួមកិច្ចប្រជុំពិភាក្សាបន្តអំពីការត្រៀមរៀបចំទិវាជាតិអន្តរសាសនាដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ចំនួន០២លើក ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ដោយមានការនិមន្ត និងអញ្ជើញចូលរួមសរុបចំនួន **៦២**អង្គ/នាក់ ស្រី**១៤**នាក់ នៅសាលប្រជុំគ.ជ.ប.ជ។<br>
- ចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការផលិតសារជាសម្លេង សម្រាប់ផ្សព្វផ្សាយតាមប្រព័ន្ធទូរស័ព្ទចល័ត(Calltune) នាឱកាសប្រារព្ធទិវាអន្តរសាសនា លើកទី៧ ជាមួយតំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានអ្នកចូលរួម **១០**នាក់ ស្រី០២នាក់ នៅសាលប្រជុំគ.ជ.ប.ជ។<br>
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយអនុសញ្ញាអាស៊ានស្តីពី ការប្រឆាំងនឹងការជួញដូរមនុស្សជាពិសេស ស្ត្រីនិងកុមារ (ACTIP) សហការរៀបចំដោយក្រសួងយុត្តិធម៌ និងកម្មវិធីអាស៊ានអូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស នៅបណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា មានអ្នកចូលរួមចំនួន **៤៥**នាក់ ស្រី **១២**នាក់។<br>
- ចូលរួមកិច្ចប្រជុំបច្ចេកទេសជាមួយក្រុមការងារនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីពិភាក្សាអំពីការរៀបចំយន្តការបញ្ជូនជនរងគ្រោះថ្នាក់ជាតិ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ មានអ្នកចូលរួមចំនួន **០៧**នាក់ ស្រី**០៣**នាក់។<br>
- សិក្ខាសាលាបញ្ចប់សេចក្តីព្រាងផែនការសកម្មភាព ស្តីពីសុខភាពជនសន្តប្រវេសន៍ ឆ្នាំ២០២៣ ២០២៥-សហការរៀបចំដោយក្រសួងសុខាភិបាល និងអង្គការ IOM សិក្ខាសាលានេះផងដែរមានសមាសភាពចូលរួមចំនួន៣ប្រទេស(កម្ពុជា ថៃ ឡាវ) មានអ្នកចូលរួមសរុប **៦៩**នាក់។<br>
- ចូលរួមកិច្ចប្រជុំស្តីពីលទ្ធផលនៃការពិនិត្យ លើកំណែព្រះរាជក្រឹត្យ អនុក្រឹត្យ និងសេចក្តីសម្រេចផ្សេងៗ របស់ គ.ជ.ប.ជ មុនធ្វើរបាយការណ៍ជូន **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី** ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។
</td></tr>
</table>

- ចូលរួមកិច្ចប្រជុំពិភាក្សា និងកែសម្រួល លិខិតបទដ្ឋានគតិយុត្តិ ដែលមានការពាក់ព័ន្ធ និងរចនាសម្ព័ន្ធរបស់គណៈ កម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។
- ចូលរួមកិច្ចប្រជុំដើម្បីធ្វើប្រតិកម្មឆ្លើយតបទៅនឹងរបាយការណ៍របស់ការិយាល័យអង្គការសហប្រជាជាតិ (OHCHR) ក្រោមអធិបតីភាព លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។

- **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**
  - លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ៤១ច្បាប់ លិខិតចូល ៦៣ច្បាប់។
  - លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ៣៨ច្បាប់ លិខិតចូល ៤១ច្បាប់។
  - ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន ១៧០ច្បាប់។
  - អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន ១១២សកម្មភាព។
  - អាប់ឡូតឯកសារចូលបណ្ណាល័យវិគីបានចំនួន ៤៥ច្បាប់។
- **ក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់**
  - **ឯកឧត្តម អគ្គលេខាធិការរង និងលោកប្រធានក្រុម** បានចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការផលិតសារជាសម្លេង សម្រាប់ផ្សព្វផ្សាយតាមប្រព័ន្ធទូរស័ព្ទចល័ត (Calltune) នាឱកាសប្រារព្ធទិវាអន្តរសាសនា លើកទី៧ជាមួយតំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។
  - បានដាក់សំណើសុំជួយជំរុញឱ្យមានសកម្មភាពផ្សព្វផ្សាយខ្លឹមសារអប់រំ តាមរយៈសម្លេង (Calltune និងសារ (SMS) នៅគ្រប់បណ្តាក្រុមហ៊ុនផ្តល់សេវាកម្មទូរស័ព្ទចល័ត ដើម្បីអបអរសាទរទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស លើកទី៧ ឆ្នាំ២០២៣។
  - បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ គោលការណ៍ណែនាំស្តីពី កិច្ចការពារកុមារលើប្រព័ន្ធអនឡាញសម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យា ឌីជីថលនៅកម្ពុជា នៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
  - បានចូលរួមប្រជុំក្រុមគ្រូឧទ្ទេស ត្រៀមចុះទៅបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តកំពង់ចាម និងខេត្តកំពត ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចំនួន០២លើក។
  - បានចូលសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ អំពីលទ្ធផលសម្រេចបាននៃការអនុវត្តសកម្មភាពគម្រោង នៃការអភិវឌ្ឍន៍ផែនទីបន្លាស់ទីប្រជាជន ដែលរៀបចំដោយអង្គការ IOM ក្រោមជំនួយឧបត្ថម្ភមូលនិធិពីធនាគារ ADB នៅខេត្តសៀមរាប។
  - បានចូលរួមជាគ្រូឧទ្ទេស នៅក្នុងវគ្គបណ្តុះបណ្តាលស្តីពី «ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅខេត្តកំពង់ចាម មានអ្នកចូលរួមចំនួន ៤១នាក់។

- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**
  - ឯកឧត្តម អគ្គលេខាធិការរង និងលោកប្រធានក្រុម បានចូលរួមប្រជុំ ស្តីពីការត្រៀមរៀបចំសិក្ខាសាលា និងចងក្រងឯកសារផែនការសកម្មភាព ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ សម្រាប់ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥ នៅទីស្តីការក្រសួងសុខាភិបាល។
  - ចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅអង្គភាពកងកម្លាំងរក្សាសន្តិភាព នៃអនុសេនាធំលេខ៤២៣ មុនចេញបំពេញបេសកកម្មរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល នៅឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្រ្គាម ខេត្តកំពង់ស្ពឺ។
  - បានចូលរួមសិក្ខាសាលា ស្តីពីការបញ្ចប់សេចក្តីព្រាងផែនការសកម្មភាពឆ្នាំ ២០២៣-២០២៥ របស់ថ្នាក់ជាតិ លើផ្នែកសុខភាពជនទេសន្តរប្រវេសន៍ ក្រោមអធិបតីភាព ឯកឧត្តម វេជ្ជបណ្ឌិត **ស៊ា ហ៊ួង** រដ្ឋលេខាធិការ ក្រសួងសុខាភិបាល មានអ្នកចូលរួមចំនួន **៤៤**នាក់ ស្រី**០៩**នាក់ នៅខេត្តសៀមរាប ។
  - លោកប្រធាន និងលោកអនុប្រធានក្រុម បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការធ្វើបច្ចុប្បន្នភាពលើកិច្ចព្រមព្រៀងសហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាលកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្តីពីនីតិវិធីប្រតិបត្តិបទដ្ឋាន (SOP) ក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន០២លើក នៅខេត្តសៀមរាប និងខេត្តព្រះសីហនុ។
  - បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ស្តីពី ការវិវត្តន៍ផែនទីបន្លាស់ទីប្រជាជនក្នុងខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាព ឯកឧត្តម វេជ្ជបណ្ឌិត **លី សុវណ្ណ** ប្រធាននាយកដ្ឋាន ជម្ងឺឆ្លង និងជាទីប្រក្សា ក្រសួងសុខាភិបាល មានអ្នកចូលរួមចំនួន **៥០**នាក់ ស្រី**១២**នាក់ នៅខេត្តសៀមរាប។
- **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**
  - ឯកឧត្តម អគ្គលេខាធិការរង បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយអនុសញ្ញាអាស៊ានស្តីពី ការប្រឆាំងនឹងការជួញដូរមនុស្សជាពិសេស ស្ត្រី និងកុមារ (ACTIP) សហការរៀបចំដោយក្រសួងយុត្តិធម៌ និងកម្មវិធីអាស៊ានអូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស នៅបណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា។
  - ចូលរួមកិច្ចប្រជុំដើម្បីធ្វើប្រតិកម្មឆ្លើយតបទៅនឹងរបាយការណ៍របស់ការិយាល័យអង្គការសហប្រជាជាតិ (OHCHR) ក្រោមអធិបតីភាព លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។
  - ចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅអង្គភាពកងកម្លាំងរក្សាសន្តិភាព នៃអនុសេនាធំលេខ៤២៣ មុនចេញបំពេញបេសកកម្មរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល នៅឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្រ្គាម ខេត្តកំពង់ស្ពឺ។
- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**
  - **លោកជំទាវ អគ្គលេខាធិការរង** បានអញ្ជើញចូលរួម៖ **១.**ពិធីផ្សព្វផ្សាយជាផ្លូវការពីគម្រោងពហុឆ្នាំនៃ ACWC និង ឯកសារណែនាំការបណ្តុះបណ្តាលកម្រិតខ្ពស់ស្តីពីការយកចិត្តទុកដាក់លើយេនឌ័រក្នុងការងារប្រឆាំងការជួញដូរមនុស្សសម្រាប់អ្នកអនុវត្តន៍ជួរមុខ នៅទីក្រុងបាងកក ប្រទេសថៃឡង់ដ៍។ **២.**ដឹកនាំកិច្ចជុំពិភាក្សាអំពីការរៀបចំសៀវភៅណែនាំសម្រាប់ការបង្រៀនមេរៀនកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាមួយអង្គការ IJM។ ៣.បានដឹកនាំ ក្រុម

ការងារចុះត្រួតពិនិត្យការងារថតខ្សែភាពយន្តអប់រំខ្លី Can You See Me ដែលបានសហការជាមួយ អង្គការA21។ **៤.**បានដឹកនាំកិច្ចប្រជុំពិភាក្សាអំពីការកែសម្រួលទៅលើខ្លឹមសារ របាយការណ៍របស់ក្រសួងជំនាញដើម្បីបញ្ចូល ទៅក្នុងទម្រង់របាយការណ៍របស់គ.ជ.ប.ជ។ **៥.**សិក្ខាសាលាផ្សព្វផ្សាយអនុសញ្ញាអាស៊ានស្តីពី ការប្រឆាំងនឹងការជួញដូរមនុស្សជាពិសេសស្ត្រីនិងកុមារ (ACTIP) សហការរៀបចំដោយក្រសួងយុត្តិធម៌ និងកម្មវិធីអាស៊ានអូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស នៅបណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា។ **៦.**ចូលរួមកិច្ចប្រជុំបច្ចេកទេសជាមួយក្រុមការងារនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីពិភាក្សាអំពីការរៀបចំយន្តការបញ្ជូនជនរងគ្រោះថ្នាក់ជាតិក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **៧.**កិច្ចប្រជុំស្តីពីស្វែងយល់អំពីទំនោរបទល្មើសជួញដូរមនុស្សថ្មីៗ ពិភាក្សាស្វែងរកធាតុចូលសម្រាប់វគ្គផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រអាស៊ានអាក់អណត្តិថ្មី ក្រោមអធិបតីភាព លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **៨.**កិច្ចប្រជុំក្រុមគ្រូឧទ្ទេស នៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ចុះទៅបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តកំពង់ចាម និងកំពត ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **៩.**កិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីសម្រេចព្រាងអនុស្សារណៈនៃការយោគយល់ស្តីពី កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា ក្រោមអធិបតីភាពឯកឧត្តម **អ៊ុច ចាន់ណូរ៉ា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅសាលប្រជុំខេត្តសៀមរាប នៃទីស្តីការក្រសួងមហាផ្ទៃ។ **១០.**ធ្វើជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាលស្តីពី «ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅខេត្តកំពង់ចាម។

- បានរៀបចំកិច្ចប្រជុំផ្ទៃក្នុង ដើម្បីតាមដានជំរុញ ការអនុវត្ត MOU ដោយត្រូវរៀបចំជាតារាងបច្ចុប្បន្នភាព នៅក្នុងប្រព័ន្ធវីគី និងត្រូវត្រួតពិនិត្យ កែសម្រួលលើការបញ្ចូលឯកសារ TOT ដើម្បីត្រៀមរៀបចំកិច្ចប្រជុំពិភាក្សាឆ្លងយោបល់ សម្រាប់ក្រុមការងារទាំង៦ ដែលពាក់ព័ន្ធ។
- លោកប្រធានក្រុម បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យវឌ្ឍនភាព និងផ្ទៀងផ្ទាត់ទិន្នន័យដែលមានក្នុងការវាយតម្លៃនិងអនុសាសន៍របស់ក្រសួងការបរទេសអាមេរិកសម្រាប់កម្ពុជា ពាក់ព័ន្ធនិងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២៣។

- **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**

- ឯកឧត្តម អគ្គលេខាធិការរង បានចូលរួមកិច្ចប្រជុំគណៈកម្មការប្រឹក្សាយោបល់ ក្នុងការអនុវត្តកម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍ នៅសណ្ឋាគារភ្នំពេញ។
- លោកប្រធានក្រុម បានចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការផលិតសារជាសម្លេង សម្រាប់ផ្សព្វផ្សាយតាមប្រព័ន្ធទូរស័ព្ទចល័ត (Calltune) នាឱកាសប្រារព្ធទិវាអន្តរសាសនា លើកទី៧ជាមួយតំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។

| លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៧៣លើក អ្នកចូលរួមសរុបចំនួន ២.៤៧៧នាក់(ស្រី ១.២៧៥នាក់) | |
|---|---|
| **ខេត្តកណ្តាល** | - លោកជំទាវ **ហ៊ុន កុសនី** អភិបាលរង និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានធ្វើជាគណៈអធិបតីបើកវគ្គបណ្តុះបណ្តាលស្តីពី ការឆ្លើយតប និងសេវាគាំទ្របែបកុមារមេត្រី នៅដំណាក់កាលអន្តរាគមន៍វិបត្តិសម្រាប់កុមាររងគ្រោះនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ដោយមានការឧបត្ថម្ភគាំទ្រពីអង្គការសកម្មភាពដើម្បីកុមារ (APLE) ធ្វើនៅសាលប្រជុំសាលាខេត្ត មានអ្នកចូលរួមសរុបចំនួន **៦០**នាក់ ស្រី**២៦**នាក់។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ រៀបចំកិច្ចប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ **០៥**លើក មានអ្នកចូលរួម **១៩៣**នាក់ ស្រី**៨១**នាក់។<br>- ក្រុមការងារក្រុង-ស្រុក ប្រជុំប្រចាំខែ ចំនួន **១៨**លើក អ្នកចូលរួម **៤៣៦**នាក់ ស្រី**២១៦**នាក់។ |
| **ខេត្តកំពង់ចាម** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យលទ្ធផលការងារប្រចាំខែ **០២**លើក អ្នកចូលរួម **៤០**នាក់ ស្រី**២៣**នាក់។ |
| **ខេត្តកំពង់ធំ** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ចំនួន **០១**លើក មានអ្នកចូលរួម **៤០**នាក់ ស្រី**២៤**នាក់។ |
| **ខេត្តកំពង់ឆ្នាំង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែ **០១**លើក។ |
| **ខេត្តបន្ទាយមានជ័យ** | - ប្រធានលេខាធិការដ្ឋានខេត្ត បានចូលរួមសម្របសម្រួលក្នុងកិច្ចប្រជុំឆមាសទី១ ឆ្នាំ២០២៣ អាណត្តិទី៣ របស់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារខេត្ត បានស្នើដល់សមាភាពដែលអញ្ជើញចូលរួមឱ្យជួយបន្តផ្សព្វផ្សាយ អំពីច្បាប់នៃការជួញដូរមនុស្សនៅកម្ពុជា ឱ្យបានទៅដល់មូលដ្ឋាន ជាពិសេសស្ត្រី និងកុមារ អ្នកចូលរួមសរុប **៣៥**នាក់ ស្រី**២៧**នាក់។<br>- លោកស្រីឧត្តមសេនីយ៍ត្រី ស្នងការរង បានសម្របសម្រួលចូលរួមប្រជុំ ប្រមូលធាតុចូល និងផ្សព្វផ្សាយរបាយការណ៍ ស្តីពីការសិក្សាវិភាគពីស្ថានភាពការកេងប្រវញ្ច័លើកុមារនៅកម្ពុជា។ |
| **ខេត្តសៀមរាប** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែ **០២**លើក មានអ្នកចូលរួម **១២២**នាក់ ស្រី**៦៤**នាក់។<br>- ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំ **១៧**លើក មានអ្នកចូលរួម **៤៣៣**នាក់ ស្រី**១៧៥**នាក់។ |
| **ខេត្តត្បូងឃ្មុំ** | - មន្ត្រីជំនាញនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស នីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ក្នុងការសម្ភាសន៍ នៅខេត្តកំពង់ចាម ដែលរៀបចំដោយអង្គការសម្ព័ន្ធចាប់ដៃ មានសិក្ខាកាមចូលរួម **៣៥**នាក់ ស្រី**២៣**នាក់។ |
| **ខេត្តស្វាយរៀង** | - បានចូលរួមកិច្ចប្រជុំ វឌ្ឍនភាពការងារកិច្ចការពារកុមារប្រចាំឆមាសទី១ ឆ្នាំ២០២៣ នៅសាលាស្រុករមាសហែក មានអ្នកចូលរួមចំនួន ៤០នាក់។<br>- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីសុវត្ថិភាពកុមារ និងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ ក្នុងវិស័យទេសចរណ៍ខេត្ត មានចូលរួមចំនួន ៨០នាក់។<br>- បានចូលរួមសិក្ខាសាលាស្តីពី យន្តការបញ្ជូនបន្តថ្នាក់ជាតិពាក់ព័ន្ធអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសណ្ឋាគារកាំបូឌីយ៉ាណារាជធានីភ្នំពេញ អ្នកចូលរួម ៦០នាក់ ស្រី៣៥នាក់។ |

| | |
|---|---|
| ស្ទឹងត្រែង | - បានរៀបចំកិច្ចប្រជុំប្រចាំឆមាសទី១ និងត្រីមាសទី៣ ឆ្នាំ២០២៣ ចំនួន០២លើក អ្នកចូលរួមចំនួន៧២នាក់ ស្រី៥៤នាក់។ |
| ខេត្តព្រះវិហារ | - បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី២ ចំនួន០១លើក អ្នកចូលរួមចំនួន១៧នាក់ ស្រី០៨នាក់។ |
| ខេត្តព្រៃវែង | - បានរៀបចំកិច្ចប្រជុំប្រចាំខែ ចំនួន០១លើក អ្នកចូលរួមចំនួន៩៩នាក់។<br>- រៀបចំកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្តចំនួន ០២លើក មានអ្នកចូលរួមសរុប ២០៥នាក់។<br>- សហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី រៀបចំកិច្ចប្រជុំស្តីពី ការកសាងបណ្តាញការងារជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូ មានអ្នកចូលរួម ១៥នាក់ ស្រី០៤នាក់។ |
| ខេត្តកំពត | - បានរៀបចំកិច្ចប្រជុំប្រចាំខែ ០២លើក ផ្សព្វផ្សាយលិខិតបទដ្ឋានថ្មីៗ ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន ៥៨នាក់ ស្រី៣០នាក់។<br>- ០១លើក ២៩ ១៥ |
| ខេត្តពោធិ៍សាត់ | - លោកជំទាវអភិបាលរងខេត្ត បានដឹកនាំកិច្ចប្រជុំពិភាក្សាលើផែនការការងារ ជាមួយអង្គការដៃគូ ០១លើក។<br>- គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ជ.ប.ខ.គ)បានប្រជុំប្រចាំឆមាសទី១ ឆ្នាំ២០២៣ ចំនួន ០១លើក។ |
| ខេត្តកោះកុង | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំត្រៀមរៀបចំផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅស្រុកបូទុមសាគរ ស្រុកគិរីសាគរ និងស្រុកថ្មបាំង និងត្រៀមរៀបចំទិវាជាតិ១២ធ្នូ ឆ្នាំ២០២៣ ចំនួន០១លើក មានអ្នកចូលរួម ០៦នាក់ ស្រី០៥នាក់ នៅសាលាខេត្តកោះកុង។ |
| ខេត្តក្រចេះ | - តំណាងស្នងការដ្ឋាននគរបាល ផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននិងការងារយេនឌ័រ បានចូលរួមធ្វើបទបង្ហាញដល់នគរបាលទើបជ្រើសរើសថ្មី ចំនួន៧៤នាក់ ស្រី២៣នាក់ លើប្រធានបទ ការទប់ស្កាត់អំពើជួញដូរមនុស្សនិងកិច្ចការពារកុមារ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ។<br>- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចូលរួមសហការជាមួយក្រុមការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការងារនគរបាលអន្តរជាតិ FBI ធ្វើការសម្ភាសន៍បែបកោសល្យវិច្ច័យជាមួយកុមាររងគ្រោះដោយការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ បានចំនួន០៧នាក់ ។ |
| ខេត្តបាត់ដំបង | - ចូលរួមជាអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានា និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ០១លើក នៅមន្ទីរកិច្ចការនារីខេត្ត។<br>- ចូលរួមកិច្ចប្រជុំត្រីមាសទី៣ ស្តីពីវឌ្ឍនភាពរបស់មណ្ឌល និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធ នៅមណ្ឌលទទួលពលករកំរៀង។<br>- ចូលរួមកិច្ចប្រជុំថ្នាក់បច្ចេកទេសស្តីពី ប្រព័ន្ធបញ្ជូនជនរងគ្រោះថ្នាក់ជាតិពាក់ព័ន្ធអំពើជួញដូរមនុស្ស នៅរាជធានីភ្នំពេញ ០១លើក។<br>- ចូលរួមប្រជុំពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយអង្គការវីនរ៉ក់ ០១លើក។<br>- ចូលរួមធ្វើបទបង្ហាញស្តីពី សុវត្ថិភាពទេសសន្តរប្រវេសន៍នៅមូលដ្ឋាន និងផែនការផ្សព្វផ្សាយអប់រំរបស់ជនបង្គោល នៅមណ្ឌលទទួលពលករកំរៀង សហការរៀបចំដោយអង្គការការីតាស់ស្វីស មានអ្នកចូលរួម ៣៨៦នាក់ ស្រី២៦៧នាក់។<br>- បានចូលរួមបណ្តុះបណ្តាលវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការសម្ភាសន៍បែបកោសល្យវិច័យ ០១លើក។ |